អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គភាពគាំពារជនរងគ្រោះ
Victims Support Section
Section d'appui aux victimes

ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១០

# សេចក្តីប្រកាសព័ត៌មាន

## អង្គភាពគាំពារជនរងគ្រោះត្រៀមរៀបចំសម្រាប់ការជំនុំជម្រះក្នុងសំណុំរឿង០០២របស់អ.វ.ត.ក

អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(អ.វ.ត.ក)បានចាប់ផ្តើមចាត់វិធានការចាំបាច់នានា ក្នុងគោលបំណងរៀបចំសម្រួលដល់ការចូលរួមរបស់ជនរងគ្រោះ ដែលមានចំនួនដ៏ច្រើនសន្ធឹកសន្ធាប់ ពិសេសដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការជំនុំជម្រះសំណុំរឿង០០២ នាពេលខាងមុខនេះ។

ការវិវឌ្ឍថ្មីៗ ក្នុងអង្គភាពគាំពារជនរងគ្រោះ បង្ហាញនូវការត្រៀមខ្លួនរួចជាស្រេចរបស់អង្គភាពដើម្បីសម្រេចឲ្យបាននូវបេសកកម្មរបស់ខ្លួនសម្រាប់ការជំនុំជម្រះសំណុំរឿង០០២។

### បុគ្គលិក ធនធាន និងយុទ្ធសាស្ត្រ

ប្រធានអង្គភាពគាំពារជនរងគ្រោះ ដែលជាអតីតមន្ត្រីទទួលបន្ទុកជំនួសសម្រាប់រយៈពេលខ្លីបច្ចុប្បន្ន កំពុងកាន់មុខតំណែងនេះពេញលេញទាំងស្រុង។ បន្ថែមលើនេះទៀត ប្រធានកម្មវិធីផ្សព្វផ្សាយដែលទើបជ្រើសរើសថ្មីក៏បានចាប់ផ្តើមការងាររបស់លោក នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០នេះផងដែរ។ ជាមួយនឹងបុគ្គលិកដែលមានស្រាប់នៅអង្គភាព ក្រុមការងារថ្មីនេះនឹងពង្រឹងកម្រិតនៃការចូលរួមរបស់ជនរងគ្រោះ ខណៈដែលតុលាការកំពុងត្រៀមខ្លួនចូលដំណាក់កាលថ្មីនៃនីតិវិធីក្នុងសំណុំរឿង០០២ បន្ទាប់ពីការចេញដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត។ ដើម្បីធានានូវលទ្ធផលវិជ្ជមាន និងផលប៉ះពាល់នៃការងាររបស់ខ្លួន អង្គភាពគាំពារជនរងគ្រោះបានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុពីម្ចាស់ជំនួយនានាជាបន្តបន្ទាប់ ដើម្បីជួយឲ្យអង្គភាពនេះបំពេញអាណត្តិរបស់ខ្លួនបានពេញលេញ។

ថ្មីៗនេះ អង្គភាពគាំពារជនរងគ្រោះបានរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់រយៈពេល៣ឆ្នាំ (២០១១-២០១៣) របស់ខ្លួន ដើម្បីបម្រើជាផែនទីផ្លូវមួយ សម្រាប់តម្រង់ទិសដៅសកម្មភាពនានារបស់ខ្លួន ក្នុងគោលបំណងត្រៀមរៀបចំចាត់ចែងជាមួយនឹងបញ្ហាប្រឈមនានា និងនិន្នាការដែលអាចនឹងកើត

ឡើងថ្មីៗ ក្នុងនោះរួមមានការចូលរួមដ៏ច្រើនសន្ធឹកសន្ធាប់នៃជនរងគ្រោះក្នុងដំណើរការនីតិវិធី សកម្មភាពផ្សព្វផ្សាយ បញ្ហាសំណង និងវិធានការមិនពាក់ព័ន្ធនឹងបច្ចេកទេសតុលាការ។ បច្ចុប្បន្ន អង្គភាពកំពុងធ្វើការប្រឹក្សាយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីធ្វើសុខដុមនីយកម្មផែនការសកម្មភាពទាំងនេះ ។ ផែនការដែលបានច្របាច់បញ្ចូលគ្នា និងប្រឹក្សាយោបល់នេះនឹងបម្រើជាប្រទីបសម្រាប់សកម្មភាពនានារបស់អង្គភាព និងសម្រាប់កិច្ចសហការរបស់ខ្លួនជាមួយនឹងដៃគូ រួមមានអង្គភាព/ផ្នែកផ្សេងៗទៀតរបស់តុលាការ មេធាវី និងអង្គការសង្គមស៊ីវិល។

### ការចូលរួមរបស់ជនរងគ្រោះ និងកម្មវិធីផ្សព្វផ្សាយ

ក្នុងចំណោមអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៣៩៨៨នាក់ ដែលប្រាថ្នាចង់ចូលរួមក្នុងនីតិវិធីសំណុំរឿង០០២ សហចៅក្រមស៊ើបអង្កេតបានប្រកាសទទួលយក២១២៤នាក់ និងមានបណ្តឹងឧទ្ធរណ៍ប្រមាណ១៦៧០ ដែលបច្ចុប្បន្នកំពុងស្ថិតក្រោមចំណាត់ការរបស់អង្គបុរេជំនុំជម្រះ។ ទាំងអស់នេះ បើនិយាយអំពីការចូលរួមរបស់ជនរងគ្រោះ វាធ្វើឲ្យសំណុំរឿង០០២ក្លាយទៅជាសំណុំរឿងដ៏សំខាន់មួយក្នុងប្រវត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ បញ្ហាប្រឈមទាក់ទិននឹងការចូលរួមក្នុងដំណើរការនីតិវិធី និងការគ្រប់គ្រងការរំពឹងទុកមានទំហំធំធេង។ ជាមួយនឹងកិច្ចសហការយ៉ាងជិតស្និតពីសំណាក់មេធាវី និងដៃគូអង្គការសង្គមស៊ីវិល អង្គភាពគាំពារជនរងគ្រោះប្តេជ្ញាប្រើប្រាស់ឲ្យអស់សក្តានុពលនូវធនធានដ៏មានកម្រិតរបស់ខ្លួន ដើម្បីជួយដល់ជនរងគ្រោះទាំងនេះ ពិសេសដើមបណ្តឹងរដ្ឋ-ប្បវេណី និងដើម្បីធានានូវការចូលរួមដ៏មានប្រសិទ្ធភាពរបស់ពួកគាត់។ ដើម្បីដោះស្រាយបញ្ហាបដិសេធមិនទទួលយកអ្នកដាក់ពាក្យទាំងនេះក្នុងសំណុំរឿង០០២ វេទិកាសាធារណៈមួយត្រូវបាន គ្រោងរៀបចំនៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ២០១០ ខាងមុខនេះ។ វេទិកានេះនឹងអនុញ្ញាតឲ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបដិសេធទាំងអស់ជួបសន្ទនាផ្ទាល់ និងជជែកកិច្ចការពិភាក្សាជាមួយនឹងតុលាការ ក្នុងនោះរួមមានសហចៅក្រមស៊ើបអង្កេត អង្គភាពគាំពារជនរងគ្រោះ និងមេធាវីរបស់ ពួកគាត់។

### ការតំណាងផ្នែកច្បាប់

បន្ទាប់ពីវិសោធនកម្មលើវិធានផ្ទៃក្នុងអ.វ.ត.កនៅកិច្ចប្រជុំពេញអង្គលើកទី៧ (ខែកុម្ភៈ) និងទី៨ (ពាក់កណ្តាលខែកញ្ញា)មក ការិយាល័យរដ្ឋបាលត្រូវបង្កើតអង្គភាពថ្មីមួយគឺ ផ្នែកសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីធានាការរៀបចំប្រកបដោយប្រសិទ្ធភាពនៃការតំណាងឲ្យដើម-បណ្តឹងរដ្ឋប្បវេណីចាប់ពីដំណាក់កាលជំនុំជម្រះឡើងទៅ។ តំណែងសហមេធាវីនាំមុខជាតិតំណាង

ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានបំពេញដោយអតីតមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលទទួលមូលធិនិពីតុលាការ នៅថ្ងៃទី១ ខែតុលា ហើយមុខតំណែងចាស់របស់លោកក៏ត្រូវបានជ្រើសរើសបំពេញបន្ថែមរួចរាល់ផងដែរ ខណៈដែល UNAKRT កំពុងធ្វើការជ្រើសរើស សហមេធាវីនាំមុខអន្តរជាតិ។ ដើម្បីជួយគាំទ្រដល់សហមេធាវីនាំមុខទាំងពីរ ប្រធានគ្រប់គ្រងសំណុំរឿងកម្ពុជាពីរនាក់ត្រូវបានជ្រើស-រើស។ អង្គភាពគាំពារជនរងគ្រោះនឹងបន្តជួយគាំទ្រដល់សហមេធាវីនាំមុខ និង មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ ស្របទៅតាមអាណត្តិរបស់ខ្លួន ដូចមានចែងក្នុងវិធានផ្ទៃក្នុង។

### វិធានការ ដែលមិនពាក់ព័ន្ធនឹងបច្ចេកទេសតុលាការ និងសំណងផ្លូវចិត្ត និងសមូហភាព

វិសោធនកម្មបន្ថែមលើវិធានផ្ទៃក្នុងអ.វ.ត.កនៅកិច្ចប្រជុំពេញអង្គលើកទី៧ និងទី៨ បានពង្រីកអាណត្តិរបស់អង្គភាពគាំពារជនរងគ្រោះ ក្នុងវិស័យពីរបន្ថែមទៀតគឺៈ (១)អង្គភាពគាំពារជនរងគ្រោះត្រូវបានប្រគល់ភារកិច្ចឲ្យធ្វើការរៀបចំ និងអនុវត្តកម្មវិធី ព្រមទាំងវិធានការនានាដែលមិនពាក់ព័ន្ធនឹងបច្ចេកទេសតុលាការ ដើម្បីផ្ដល់ជាប្រយោជន៍ដល់ជនរងគ្រោះឲ្យកាន់តែទូលំទូលាយ។ កម្មវិធីខាងលើនេះអាចត្រូវបានរៀបចំ និងអនុវត្តដោយមានកិច្ចសហការជាមួយស្ថាប័ន ដែលស្ថិតនៅក្រៅអង្គជំនុំជម្រះវិសាមញ្ញ។ បន្ថែមលើនេះទៀត (២)វិធានថ្មីនេះក៏អនុញ្ញាតឲ្យសហមេធាវីនាំមុខស្វែងរកវិធានការសំណងផ្លូវចិត្ត និងសមូហភាពជាក់លាក់ ដែលត្រូវបានរៀបចំ ឬកំណត់ ដោយមានកិច្ចសហការជាមួយអង្គភាពគាំពារជនរងគ្រោះ និងអនុវត្ត គម្រោងដោយទទួលមូលនិធិពីខាងក្រៅ។ គម្រោងណាមួយដែលត្រូវរៀបចំ នឹងត្រូវមានកិច្ចសហការជាមួយស្ថាប័នរដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាល។ វិធានការសំណងថ្មីៗទាំងនេះ នឹងត្រូវអនុវត្តក្នុងនីតិវិធីចាប់ពីសំណុំរឿង០០២តទៅ។ អង្គភាពគាំពារជនរងគ្រោះកំពុងធ្វើការជ្រើសរើស ប្រធានគម្រោងជាតិម្នាក់ ដែលត្រូវធ្វើការជាមួយទីប្រឹក្សាអន្តរជាតិម្នាក់ ដើម្បីផ្ដល់សមត្ថភាពបឋមដល់អង្គភាពគាំពារជនរងគ្រោះ ក្នុងការចាប់ផ្ដើមអនុវត្ត អាណត្តិថ្មីទាំងពីរនេះ។

ការវិវឌ្ឍថ្មីៗ នៅអង្គភាពគាំពារជនរងគ្រោះ ដូចរៀបរាប់ខាងលើ នឹងជម្រុញឲ្យអង្គភាពជនរងគ្រោះមានកម្លាំង ក្នុងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ និងការចូលរួមដ៏សុចិតពីសំណាក់ជនរងគ្រោះតាមរយៈកម្មវិធី ព្រមទាំងវិធានការនានារបស់តុលាការ និង ដែលមិនពាក់ព័ន្ធនឹងបច្ចេកទេសតុលាការ ទាំងក្នុងអំឡុងពេលដំណើរការនីតិវិធី និងពេលបន្ទាប់មកទៀត។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមក៖**

1. លោក **អ៊ឹម សុភា** ប្រធានកម្មវិធីផ្សព្វផ្សាយរបស់អង្គភាពគាំពារជនរងគ្រោះ
ទូរស័ព្ទ 077 777 367 អ៊ីម៉ែល im.sophea@eccc.gov.kh